雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.147

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7587 ថ្ងៃសុក្រ ទី16 ខែមីនា ឆ្នាំ 2018

## ប្រទេសចិនអាចមានកំណើន GDP៦,៥ភាគរយ នៅឆ្នាំ២០១៨ ដែលបង្ហាញពីការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់

លោក លី ខឺឈាំង នាយករដ្ឋមន្ត្រីចិន បានថ្លែងរបាយការណ៍ការងាររដ្ឋាភិបាលក្នុងកិច្ចប្រជុំលើកទី ១ នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិននីតិកាលទី១៣ថា តាមការព្យាករណ៍នៅឆ្នាំ២០១៨នេះ ប្រទេសចិននឹងអាចសម្រេចបាននូវកំណើន GDP ៦,៥ភាគរយ ដែលបានបង្ហាញពីដំណើរ នៃការអភិវឌ្ឍដែលប្រកបទៅដោយគុណភាពខ្ពស់ ។



*កិច្ចប្រជុំប្រចាំឆ្នាំពីរនៃ សភាតំណាងប្រជាជនទូទាំងប្រទេស ចិននីតិកាលដែលបានដំណើរការ កាលពីថ្ងៃទី៣ ដល់៥ ខែមីនា នៅ ទីក្រុងប៉េកាំង កំពុងតែទាក់ទាញចំណាប់អារម្មណ៍ពីផ្នែកផ្សេងៗនៃពិភពលោក។ នេះគឺជាទិដ្ឋភាព ដែលប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិកំពុង តែយកព័ត៌មាននៅពេលបើកកិច្ចប្រជុំកាលពីថ្ងៃទី៥ ខែមីនា (ស៊ីនហួរ )*

របាយការណ៍នេះបានលើកឡើងតួលេខមួយចំនួនទៀតថា តម្លៃ ចំណាយរបស់ប្រជាជនចិនកើនឡើង ៣ភាគរយ ផ្តល់ឱកាសការងារថ្មីដល់ ប្រជាជននៅក្នុងទីក្រុង និងផ្សារឃុំចំនួនជាង១១លាននាក់អត្រាអត់ការងារធ្វើស្ថិតនៅក្រោមកម្រិត៥,៥ភាគរយកំណើនចំណូលប្រជាជនស៊ីសង្វាក់គ្នាទៅនឹងកំណើនសេដ្ឋកិច្ចអត្រាចំណាយថាមពលធៀបនឹងកំណើន GDP ធ្លាក់ចុះជាង ៣ភាគរយ បរិមាណនៃការបញ្ចេញជាតិបំពុលបរិស្ថានសំខាន់បន្ត ធ្លាក់ចុះ ។ល។

តាមរបាយការណ៍នេះ បានឱ្យដឹងថា គោលដៅខាងលើត្រូវបានកំណត់ដោយផ្អែកទៅលើតម្រូវការនៃដំណាក់កាលគន្លឹះសម្រាប់កសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយ ហើយស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចជាក់ស្តែងរបស់ប្រទេសចិន ដែលបានប្រែក្លាយពីដំណាក់កាលអភិវឌ្ឍន៍ដោយល្បឿនលឿនទៅជាដំណាក់កាលអភិវឌ្ឍន៍ដោយមានគុណភាពខ្ពស់ ។ បើនិយាយតាមស្ថានភាពមូលដ្ឋាននៃសេដ្ឋកិច្ចចិន និងការផ្តល់ឱកាសការងារធ្វើដល់ប្រជាជន កំណើន GDP ៦,៥ភាគរយនេះនឹងអាចផ្តល់ឱកាសការងារគ្រប់គ្រាន់ដល់ប្រជាជនចិន ។

តាមការវិភាគរបស់អ្នកជំនាញការបានឱ្យដឹងថាកំណើនGDP៦,៥ ភាគរយនេះស៊ីសង្វាក់គ្នាទៅនឹងសក្តានុពលនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសចិននាពេលបច្ចុប្បន្ន ដែលបានបង្ហាញឱ្យឃើញពីការផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍ សេដ្ឋកិច្ច ដោយមានគុណភាពខ្ពស់ និងប្រសិទ្ធផលជាក់ស្តែងមិនមែនថាគិតតែពីល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច ។ ម៉្យាងទៀត តាមតម្រូវការនៃការកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយ និងស៊ីសង្វាក់គ្នាទៅនឹងគោលដៅនៃផែនការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេល ៥ ឆ្នាំទី ១៣កំណើនGDP ៦,៥ភាគរយនេះសមស្របទៅនឹងគោលដៅប្រចាំឆ្នាំ ២០២០ដែលធ្វើឱ្យ GDP កើនឡើងទ្វេដងធៀបនឹងឆ្នាំ២០១០ ។ ការព្យាករណ៍នេះនឹងអាចជំរុញឱ្យថែរក្សាស្ថិរភាពតាមទីផ្សារ និងផ្តល់ការណែនាំកាន់តែជាក់ច្បាស់ ៕

**ដោយ ឈិន វៃវៃ (ស៊ីនហួចិន)**

## ប្រទេសចិននឹងកាត់បន្ថយភាពក្រីក្រឱ្យប្រជាជនជាង១០លាននាក់នៅឆ្នាំ ២០១៨

លោក លី ខឺឈាំង នាយករដ្ឋមន្ត្រីចិន បានថ្លែងរបាយការណ៍ការងាររដ្ឋាភិបាលក្នុងកិច្ចប្រជុំលើកទី១ នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិននីតិកាលទី១៣ ថា ឆ្នាំនេះរដ្ឋាភិបាលចិននឹងខិតខំជំរុញការកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសដែលនឹងអាចធ្វើឱ្យប្រជាកសិករជាង១០លាននាក់ជៀសផុតពីភាពក្រីក្រ និងជួយប្រជាជនក្រីក្រ២,៨លាននាក់ផ្លាស់កន្លែងរស់នៅពីតំបន់ក្រីក្រ ។



*រមណីដ្ឋាន Puzhehei នៅភាគ អាគ្នេយ៍នៃខេត្តយូនណានកំពុងតែមានភាពទាក់ទាញខណៈដែលស្ថានីយ រថភ្លើងល្បឿនលឿន យូនណាន-ក្វាងស៊ី កំពុងទទួលកំណើនភ្ញៀវទេសចរ ដែលនាំឱ្យទីនោះបានរួមវិភាគទានជាច្រើនដល់ការកាត់បន្ថយភាពក្រីក្រ (រូបថតដោយ Zhou Can )*

គិតមកដល់ចុងឆ្នាំ ២០១៧ ចំនួនប្រជាជនក្រីក្រនៅប្រទេសចិនបានធ្លាក់ចុះ១២,៨៩ លាននាក់ ចំណែកអត្រានៃការកើតមានភាពក្រីក្រគឺ៣,១ភាគរយដែលបានធ្លាក់ចុះ១,៤ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០១៦ ។ ក្រោយពីសមាជបក្សកុម្មុយនិស្តចិនលើកទី ១៨ រៀងមក ចំនួនប្រជាជនក្រីក្រនៅប្រទេសចិនបានត្រូវកាត់បន្ថយ៦៨,៥៣ លាននាក់ ដែលមានប្រជាជនក្រីក្រជាង ២ ភាគ ៣ បានជៀសផុតពីភាពក្រីក្រ ។ ប្រទេសចិនបានទទួលលទ្ធផលជាផ្លែផ្កាក្នុងការកាត់បន្ថយភាពក្រីក្រ ។

លោក វ៉ាង សានគួយ ព្រឹទ្ធបុរសនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវអំពីការកាត់បន្ថយភាពក្រីក្រនៃសាកលវិទ្យាល័យប្រជាជនចិន បានគូសបញ្ជាក់ថាបច្ចុប្បន្នការងារកាត់បន្ថយភាពក្រីក្រកំពុងជួបនឹងការលំបាកកាន់តែច្រើន ដូច្នេះគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យប្រជាជន១០លាននាក់នេះ គឺជាសមិទ្ធផលកាន់តែធំនិងសំខាន់ធៀបនឹងគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ។ យើងត្រូវចាត់វិធានការដែលកាន់តែមានប្រសិទ្ធភាព និងមានលក្ខណៈជាក់ស្តែង ដើម្បីសម្រេចបាននូវគោលដៅខាងលើនេះ ។

តាមរបាយការណ៍ការងាររដ្ឋាភិបាលបានឱ្យដឹងថា ប្រទេសចិននឹងខិតខំជំរុញការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍឧស្សាហកម្ម ការអប់រំ ការថែរក្សាសុខភាព និងការការពារអេកូ-បរិស្ថាន ហើយបំពេញការខ្វះខាតក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនិងការផ្តល់សេវាកម្មសាធារណៈ ព្រមទាំងបំផុសកម្លាំងផ្ទៃក្នុងសម្រាប់ជំរុញការកាត់បន្ថយភាពក្រីក្រ ។ ក្រៅពីនេះ ប្រទេសចិននឹងចាត់វិធានការជាក់ស្តែងសម្រាប់ផ្តល់ជំនួយឧបត្ថម្ភដល់ប្រជាជនក្រីក្រជាមនុស្សចាស់ជនពិការ និងអ្នកដែលមានជំងឺធ្ងន់ ។ ជាពិសេសប្រទេសចិននឹងខិតខំប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងដំណើរនៃការអនុវត្តការងារកាត់បន្ថយភាពក្រីក្រ និងធ្វើកំណែទម្រង់អំពីការពិនិត្យនិងតាមដានការងារកាត់បន្ថយភាពក្រីក្រ ៕

**ដោយហួរ សៀជឹង (ស៊ីនហួចិន)**

## ប្រទេសចិនទាក់ទាញអ្នកចូលចិត្តមើលសត្វស្លាបតាមរយៈទេសចរណ៍ទំនួលខុសត្រូវ

នៅពេលយើងបានធ្វើដំណើរទៅដល់តំបន់អភិរក្សធម្មជាតិថ្នាក់ជាតិភ្នំកៅលីកុង នៃខេត្តយូនណានប្រទេសចិនដើម្បីធ្វើការសិក្សាស្រាវជ្រាវរយៈពេលមួយសប្តាហ៍ អ្វីដែលមកទទួលស្វាគមន៍យើងទាំងអស់គ្នានោះគឺសំឡេងដ៏ពីរោះរណ្តំគ្រប់ប្រភេទ រួមមានសំឡេងស្រែកយំរបស់សត្វស្លាបសំឡេងទឹកហូរតាមព្រែកស្ទឹង និងសំឡេងយំរបស់សត្វរៃលើឈើ ។

សកម្មភាពគយគន់សត្វស្លាបរបស់ប្រទេសចិនកំពុងក្លាយទៅជាផ្នែកមួយនៃទីផ្សារទេសចរណ៍លើពិភពលោក ។ នៅឆ្នាំ២០០៩ សកម្មភាពគយគន់សត្វស្លាបដែលមានលក្ខណៈច្នៃប្រឌិតមួយប្រភេទបានលេចឡើងក្នុងប្រទេសចិន ពោលគឺអ្នកចូលចិត្តមើលសត្វស្លាបជួបជុំគ្នានៅក្បែរស្រះទឹកក្រោមការរៀបចំ និងគ្រប់គ្រងរបស់អ្នកស្រុកតាមតំបន់ ដើម្បីសង្កេតមើលសកម្មភាពរបស់សត្វស្លាបនៅទីនោះ ។ តាមការសិក្សាស្រាវជ្រាវប្រចាំឆ្នាំ ២០១៧ របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍តំបន់ភ្នំអន្តរជាតិ និងសាកលវិទ្យាល័យព្រៃឈើភាគនិរតីបានឱ្យដឹងថា នៅសហករណ៍ហានឡុងក្នុងភូមិប៉ៃហ្គលីងក្នុងតំបន់អភិរក្សធម្មជាតិនេះ ចំណូលរបស់អ្នកស្រុកតាមតំបន់ ដែលទទួលបានពីសកម្មភាពគយគន់សត្វស្លាបនៅស្រះទឹក មានចំនួនស្មើនឹង៧០ភាគរយនៃចំណូលសរុបរបស់ពួកគេ ។ អ្វីដែលធ្វើឱ្យយើងទាំងអស់គ្នាចាប់អារម្មណ៍យ៉ាងខ្លាំងនោះគឺ ពួកគេបានសាងសង់កន្លែងគយគន់សត្វព្រៃជុំវិញស្រះទឹក តែកន្លែងទាំងនោះស៊ីសង្វាក់គ្នាទៅនឹងទេសភាពធម្មជាតិនៅទីនោះ ហើយស្ទើរមិន ដែលប៉ះពាល់ដល់បរិស្ថានរស់នៅរបស់សត្វស្លាបទេ ។ នេះបានសឱ្យឃើញថា អ្នកស្រុកតាមតំបន់បានមានការយល់ដឹងច្បាស់លាស់ថា ការថែរក្សាបរិស្ថានឱ្យបានល្អប្រសើរនឹងអាចនាំមកនូវចំណូលដល់ពួកគេ ។

ទន្ទឹមនឹងនេះ មុខងារចម្រុះរបស់តំបន់អភិរក្សធម្មជាតិថ្នាក់ជាតិភ្នំកៅលីកុង បានធ្វើឱ្យយើងដឹងថាតំបន់អភិរក្សធម្មជាតិនេះខុសគ្នានឹងឧទ្យានជាតិធម្មតា ដែលបើកទ្វារចំពោះសាធារណជន ពីព្រោះតំបន់អភិរក្សធម្មជាតិនេះត្រូវគេបែងចែកជាច្រើនផ្នែកសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ដោយចីរភាព ហើយត្រូវមានយុទ្ធសាស្ត្រកាន់តែច្រើនសម្រាប់ទាក់ទាញទេសចរ ។ ពិតណាស់ថា "ទេសចរណ៍ទំនួលខុសត្រូវ"មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍដោយចីរភាព តែសកម្មភាពគយគន់សត្វស្លាបដ៏ពិសេសនេះនឹងអាចជួបនឹងបញ្ហាប្រឈមកាន់តែច្រើននៅពេលខាងមុខពីព្រោះទេសចរកាន់តែច្រើននឹងមកទស្សនាតំបន់នេះ ចំណែករថយន្ត និងទេសចរដែលកំពុងមានចំនួនកើនឡើងជាបន្តបន្ទាប់នោះ នឹងអាចប៉ះពាល់ដល់ការរស់នៅរបស់សត្វព្រៃ ។ ដូច្នេះស្ថាប័នពាក់ព័ន្ធគួរតែបង្កើតប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈចម្រុះដើម្បីចៀសវាងកុំឱ្យកើតមានបញ្ហាខាងលើ ៕ ***ដោយ ឌីផា បាសទីត និង អ៊ូ នីង (កាសែត Global Times)***

## ទិវាសម្លៀកបំពាក់ខេត្តយូនណាន អាគបង្ហាញម៉ូតសម្លៀកបំពាក់ចាស់បុរាណជាងគេលើពិភពលោក



*ស្ត្រីជនជាតិ យីកំពុងតែរាំរបាំ នៅក្នុងអំឡុងពិធីបុណ្យចូលឆ្នាំថ្មីៗនេះ (រូបថតដោយ Chen Fei )*

នៅថ្ងៃទី១៥ ខែ១ ជារៀងរាល់ឆ្នាំតាមចន្ទគតិចិន អ្នកស្រុកនៅភូមិជីជូ នឹងរៀបចំនិងអបអរសាទរទិវាសម្លៀកបំពាក់ជនជាតិយី ។ ឆ្នាំនេះ ទិវាសម្លៀកបំពាក់ជនជាតិយីត្រូវបានរៀបចំនៅថ្ងៃ ទី២ ខែមីនា ។ ក្នុងឱកាសទិវានេះ ទោះជាលោកយាយដែលមានអាយុជាង៩០ឆ្នាំឬក្មេងៗដែលមិនទាន់ចេះដើរសុទ្ធតែនឹងស្លៀកពាក់សម្លៀកបំពាក់ដ៏ស្រស់ស្អាតដើម្បីចូលរួមអបអរសាទរទិវាដ៏សំខាន់នេះ។ តាមការឧទ្ទេសនាមបានឱ្យដឹងថា ទិវាសម្លៀកបំពាក់ជនជាតិយីនេះចាប់ផ្តើម ពីឆ្នាំ៦៦៦ នៃគ្រិស្តសករាជ ។ នៅថ្ងៃ ទី១៥ ខែមួយជារៀងរាល់ឆ្នាំជនជាតិយីគ្រប់ៗគ្នានឹងជួបជុំគ្នាយ៉ាងសប្បាយរីករាយ ហើយស្លៀកពាក់សម្លៀកបំពាក់ដ៏ស្រស់ស្អាតរួមគ្នាច្រៀងចម្រៀង និងរាំរបាំដើម្បីបង្ហាញសម្លៀកបំពាក់ដ៏ស្រស់ស្អាតរបស់ខ្លួន ។ ក្នុងរយៈពេល ១៣៥២ ឆ្នាំកន្លងទៅនោះ ទិវា សម្លៀកបំពាក់ជនជាតិយី ដែលត្រូវគេ សន្មតជា "អាគបង្ហាញម៉ូតសម្លៀកបំពាក់ចាស់បុរាណជាងគេលើពិភពលោក" នោះ បានត្រូវរៀបចំជារៀងរាល់ឆ្នាំ និងបានបង្ហាញឱ្យឃើញពីក្តីសង្ឃឹម ដ៏ល្អបវររបស់ជនជាតិយីអំពីការស្វែងរកជីវភាពរស់នៅដ៏មានសុភមង្គល ៕

## យន្តហោះប្រភេទ C ៩១៩របស់ប្រទេសចិនបានត្រូវគេបញ្ជាទិញ ៨១៥ គ្រឿង

ពេលថ្មីៗនេះ លោកអ៊ូ ក្វាងហួយ អគ្គវិស្វករឌីហ្សែនយន្តហោះប្រភេទC ៩១៩ របស់ប្រទេសចិនបានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថាយន្តហោះ ៩១៩ នេះបានត្រូវអតិថិជនក្នុងស្រុកចំនួន២៨ បញ្ជាទិញបាន ៨១៥គ្រឿង ។ នៅពេលខាងមុខប្រទេសចិន នឹងបន្តផលិតយន្តហោះធំជាង៩១៩ដូចជាយន្តហោះប្រភេទ៩២៩ជាដើម ។

លោកបន្តទៀតថា សព្វថ្ងៃវិស្វករចិនកំពុងសាកល្បងយន្តហោះទី ១ ដោយយកទឹកជំនួសអ្នកដំណើរ ដើម្បីដាក់លើកន្លែងអង្គុយលើយន្តហោះ និងវិភាគចំពោះការប៉ះពាល់ចំពោះការហោះហើរដែលបណ្តាលមកពីកន្លែងអង្គុយរបស់អ្នកដំណើរលើយន្តហោះ ។ នៅពេលខាងមុខគេនឹងបន្តសាកល្បងវិស័យផ្សេងៗ ដើម្បីធានាឱ្យយន្តហោះថ្មីហោះហើរដោយមានសុវត្ថិភាព ។

លោកសង្កត់ធ្ងន់ថា សព្វថ្ងៃយើងបានលើកសំណើសុំអំពីការហោះហើរ EASA ទីបអឺរ៉ុបហើយបានសាកល្បងហោះហើរ២លើក។ក្រៅពីនេះយន្តហោះធំរបស់ប្រទេសចិនក៏បានទទួលសមិទ្ធផលថ្មីជាច្រើនទៀត។សព្វថ្ងៃយើងកំពុងទទួលការពិនិត្យរួមពីស្ថាប័នអាកាសចរណ៍ ស៊ីវិលចិននិងអាជ្ញាធរគ្រប់គ្រងការ ហោះហើរទ្វីបអឺរ៉ុបដើម្បីធានាឱ្យយន្តហោះរបស់យើងហោះហើរដោយជោគជ័យនិងមានសុវត្ថិភាព៕ **ដោយគួជីងតាន(ស៊ីនហួចិន)**